# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ/អ.ជ.ត.ក ( )

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 10-Jan-2013, 13:05
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ សាធារណៈ/Public

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សារណាតបរបស់ អៀង សារី ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងសាទុក្ខរបស់គាត់ជំទាស់នឹងសេចក្ដីសម្រេចដោយផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូងបដិសេធសិទ្ធិរបស់គាត់ដើម្បីមានវត្តមាននៅក្នុងបន្ទប់សវនាការ និងហាមឃាត់មិនឲ្យមានការថតវីដេអូចំពោះរូបគាត់នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ**

---

**ដាក់ដោយ:**

**សហមេធាវី:**

អាង ឧត្តម

Michael G. KARNAVAS

**អង្គជំនុំជម្រះតុលាការកំពូល:**

**ចៅក្រម គង់ ស្រីម**

**ចៅក្រម សោម សិរីវឌ្ឍ**

**ចៅក្រម Agnieszka KLONOWIECKA-MILART**

ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម **Chandra Nihal JAYASINGHE**
ចៅក្រម យ៉ា ណារិន
ចៅក្រម **Florence Ndepele Mwachande MUMBA**

សហព្រះរាជអាជ្ញា៖
ជា លាង
Andrew CAYLEY

ក្រុមមេធាវីការពារក្ដីទាំងអស់
ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់

តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) លោក អៀង សារី សូមធ្វើការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងទម្រង់នៃការចូលរួម និងការថតវីដេអូនៅក្នុងបន្ទប់ឃុំខ្លួននៅក្រោមសាលសវនាការ (“ចម្លើយតប”)[1] ដោយអនុលោមតាមមាត្រា ៨.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក។ សារណាតបនេះមានភាពចាំបាច់ដើម្បីលើកឡើងអំពីអំណះអំណាងពុំត្រឹមត្រូវ ដែលគ្មានមូលដ្ឋានច្បាស់លាស់ និងនាំឲ្យមានការភ័ន្តច្រឡំ ដែលធ្វើឡើងដោយ ក.ស.ព នៅក្នុងចម្លើយតបរបស់ខ្លួន។

I. **សារណាតប**

*ប្រវត្តិនីតិវិធី-ចម្លើយតប កថាខណ្ឌ ៣-១២*

១. នៅក្នុងកថាខណ្ឌ ៣-១២ ក.ស.ព លើកឡើងអំពីប្រវត្តិនីតិវិធី។ ជាទូទៅ ប្រវត្តិនីតិវិធីនេះមានភាពត្រឹមត្រូវ បើទោះបីជាពុំទាន់ពេញលេញ ហើយផ្នែកខ្លះធ្វើឲ្យមានការភ័ន្តច្រឡំក៏ដោយ។ ជាឧទាហរណ៍ នៅក្នុងកថាខណ្ឌ ៥ ក.ស.ព គូសបញ្ជាក់ថា នៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១២ វេជ្ជបណ្ឌិត លឹម ស៊ីវុតថា បានផ្តល់អនុសាសន៍ថាលោក អៀង សារី អាចចូលរួមក្នុងកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ វេជ្ជបណ្ឌិត លឹម ស៊ីវុតថា ពិតជាបានផ្តល់អនុសាសន៍នេះមែន ប៉ុន្តែគឺដោយសារកាលពីពេលនោះ លោក អៀង សារី កំពុងជាសះស្បើយពីជំងឺផ្តាសាយ និងជំងឺរលាកទងសួត[2]។ អនុសាសន៍នេះ *ពុំមែន* ជាអនុសាសន៍ជាទូទៅដើម្បីអនុវត្តក្នុងអំឡុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះ*ទាំងមូល*ឡើយ។ ក.ស.ព ក៏ខកខានពុំបានលើកឡើងអំពីអង្គហេតុសំខាន់ៗ នៅក្នុងប្រវត្តិនីតិវិធីរបស់ខ្លួនផងដែរ ដូចជាការពិតដែលថា វេជ្ជបណ្ឌិតតំណាងគណៈកម្មការគ្រប់គ្រងនៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតសម្រាប់ការពិនិត្យសុខភាពរបស់ជនជាប់ចោទនៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក បានផ្តល់សក្ខីកម្មនៅតុលាការបន្ទាប់ពីលោក អៀង សារី បានចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ[3]។

---

[1] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងទម្រង់នៃការចូលរួម និងការថតវីដេអូ នៅក្នុងបន្ទប់ឃុំខ្លួននៅក្រោមសាលសវនាការ, ថ្ងៃទី ៣ ខែ មករា ឆ្នាំ ២០១៣, ឯកសារ E238/9/1/2។

[2] ប្រតិចារឹក, ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១២, ឯកសារ E1/75.1, ទំព័រ ៨។

[3] *សូមមើល* ប្រតិចារឹក, ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២, ឯកសារ E1/125.1។

Original EN: 00877103-00877109

*ភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខ ដោយអនុលោមតាមវិធាន ១០៤(៤)(ក) - ចម្លើយតប កថាខណ្ឌ ១៣-១៦*

២. នៅក្នុងកថាខណ្ឌ ១៣ ក.ស.ព អះអាងថា ការបកស្រាយរបស់មេធាវីការពារក្តីអំពីវិធាន ១០៤(៤)(ក) គឺពុំត្រឹមត្រូវ និងទទួលយកបណ្តឹងសាទុក្ខ "តាមរយៈការដាក់ជំនួសនូវជំនឿអត្តនោម័តិសុទ្ធសាធ និងគ្មានមូលដ្ឋានរបស់មេធាវីការពារក្តីសម្រាប់លក្ខខណ្ឌតម្រូវខាងផ្លូវច្បាប់សត្យានុម័តិ"។ ចំណុចនេះពុំត្រឹមត្រូវទេ។ អំណះអំណាងរបស់មេធាវីការពារក្តីដែលថា កិច្ចដំណើរការនីតិវិធីនឹងត្រូវបានបញ្ចប់ដោយប្រសិទ្ធភាពសម្រាប់លោក អៀង សារី ប្រសិនបើគាត់ត្រូវបានបង្ខំឱ្យបន្តស្ថិតនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ដែលគាត់ពុំអាចតាមដានកិច្ចដំណើរការនីតិវិធី គឺផ្អែកទៅលើការសង្កេតរបស់វេជ្ជបណ្ឌិតព្យាបាលរបស់លោក អៀង សារី ដែលថា គាត់ពុំអាចផ្តង់ស្មារតីបានយូរ ព្រមទាំងការសង្កេតរបស់មេធាវីការពារក្តីអំពីសមត្ថភាពរបស់លោក អៀង សារី ក្នុងការផ្តង់អារម្មណ៍[4]។ ការបកស្រាយវិធាន ១០៤(៤)(ក) ថាវិធាននេះគ្របដណ្តប់ទៅលើស្ថានភាពនានា ដែលកិច្ចដំណើរការនីតិវិធីនឹងត្រូវបានបញ្ចប់*ដោយប្រសិទ្ធភាព* គឺជាការចាំបាច់ដើម្បីការពារសិទ្ធិជាសារវ័ន្តរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងត្រូវបានតម្រូវដោយវិធាន ២១[5]។ ការបកស្រាយនេះពុំអនុញ្ញាតឱ្យមានការទទួលយកបណ្តឹងសាទុក្ខណាមួយ ដែលធ្វើឡើងតាមតែការនឹកឃើញរបស់ជនជាប់ចោទ ដូចការអះអាងរបស់ ក.ស.ព ឡើយ។

៣. នៅក្នុងកថាខណ្ឌ ១៤ ក.ស.ព អះអាងថា ការវាយតម្លៃរបស់មេធាវីការពារក្តីអំពីស្ថានភាពវេជ្ជសាស្ត្ររបស់លោក អៀង សារី "មានការខ្វែងគ្នាគួរឱ្យកត់សម្គាល់ពីការវាយតម្លៃបច្ចុប្បន្នទាំងរបស់គ្រូពេទ្យព្យាបាល និងទាំងរបស់អ្នកជំនាញដែលបានតែងតាំងដោយអង្គជំនុំជម្រះ..."។ ដើម្បីគាំទ្រអំណះអំណាងនេះ ក.ស.ព តាមការពិតពុំបានលើកយកការវាយតម្លៃ*នានា* របស់គ្រូពេទ្យព្យាបាលលោក អៀង សារី មកធ្វើជាសំអាងឡើយ។ ជំនួសមកវិញ ក.ស.ព បានត្រឹមតែយោងទៅលើរបាយការណ៍មុនពេលចូល

---

[4] *សូមមើល* បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះក្នុងការបដិសេធសិទ្ធិរបស់ អៀង សារី ក្នុងការចូលរួមដំណើរការនីតិវិធីពីបន្ទប់សវនាការ និងការហាមឃាត់មិនឱ្យថតវីដេអូនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២, ឯកសារ E238/9/1 ("បណ្តឹងសាទុក្ខ") n. 60។

[5] *សូមមើល ឯកសារយោងខាងលើ,* កថាខណ្ឌ ២៦-៣១។

Original EN: 00877103-00877109

សម្រាកព្យាបាលនៅមន្ទីរពេទ្យចុះថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០១២ ដែលហួសកាលវេលារបស់សាស្ត្រាចារ្យ Campbell និងវេជ្ជបណ្ឌិត Fazel និង វេជ្ជបណ្ឌិត ហួត និងរបាយការណ៍មួយនៅពេលក្រោយមកទៀត ដែលចុះថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ របស់សាស្ត្រាចារ្យ Campbell[6]។ គ្រូពេទ្យព្យាបាលរបស់លោក អៀង សារី ពុំបានឈានដល់ការសន្និដ្ឋាន ដូចការសន្និដ្ឋានរបស់សាស្ត្រាចារ្យ Campbell ឬវេជ្ជបណ្ឌិត Fazel និងវេជ្ជបណ្ឌិត ហួត ឡើយ[7]។ វេជ្ជបណ្ឌិត លឹម ស៊ីវុតថា និងវេជ្ជបណ្ឌិត គី ប៊ុស្សរ បានទទួលស្គាល់ថាលោក អៀង សារី ពុំមានសមត្ថភាពដើម្បីផ្ចង់អារម្មណ៍ឱ្យបានលើសពី ១០-១៥ នាទីឡើយ ក្នុងពេលមួយលើកៗ[8]។

៤. ដោយលើកយកសាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង *Strugar* នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី មកធ្វើជាសំអាង នៅក្នុងកថាខណ្ឌ ១៤ ក.ស.ព ក៏បានអះអាងថា អំណះអំណាងរបស់មេធាវីការពារក្តីអំពីស្ថានភាពសុខភាពរបស់លោក អៀង សារី អាចពុំត្រូវបានផ្តល់ទម្ងន់ជាភស្តុតាងវេជ្ជសាស្ត្រឡើយ។ សាលដីកាក្នុងសំណុំរឿង *Strugar* ដែល ក.ស.ព បានលើកមកធ្វើជាសំអាងនេះ ពុំគាំទ្រអំណះអំណាងនេះទេ។ សាលដីកាក្នុងសំណុំរឿង *Strugar* ពុំបានលើកឡើងថាតើមេធាវីការពារក្តី អាចផ្តល់ភស្តុតាងវេជ្ជសាស្ត្រដែរ ឬយ៉ាងណាឡើយ ប៉ុន្តែជំនួសមកវិញ សាលដីកានេះគូសបញ្ជាក់ថា ត្រឹមតែការសន្មតថា អង្គជំនុំជម្រះសាលាដំបូងបានខកខានពុំបានផ្តល់សារៈសំខាន់គ្រប់គ្រាន់ទៅភស្តុតាងទំនងជាត្រូវបានបដិសេធ[9]។ មេធាវីការពារក្តីពុំបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានខកខានពុំបានផ្តល់សារៈសំខាន់គ្រប់គ្រាន់ ទៅដល់ការសង្កេតរបស់មេធាវីការពារក្តីអំពីសុខភាពរបស់លោក អៀង សារី ឡើយ។ ប៉ុន្តែ មេធាវីការពារក្តីបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានបំពានឆន្ទានុសិទ្ធិរបស់ខ្លួន តាមរយៈការផ្តល់សារៈសំខាន់ទៅលើការពិចារណាអំពីចំណុចពុំពាក់ព័ន្ធ ឬ

---

[6] សូមកត់សម្គាល់ថា ក.ស.ព បានយោងពុំត្រឹមត្រូវទៅលើឯកសារ E11/86/L, ដែលពុំមែនជាលេខឯកសារដែលមានសុពលភាពជំនួសឱ្យឯកសារ E11/86/1។

[7] *សូមមើល* សំណើរបស់អៀង សារី ស្នើសុំឱ្យមានការពិចារណាឡើងវិញអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានសម្រេចថា គាត់មានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការ និងដែលបដិសេធសំណើរបស់គាត់ដែលស្នើសុំការតែងតាំងអ្នកជំនាញបន្ថែមដើម្បីជួយកំណត់អំពីសម្បទា, ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១២, ឯកសារ E238/11, កថាខណ្ឌ ២២-២៨។

[8] ប្រតិចារឹក, ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២, ឯកសារ E1/125.1, ទំព័រ ៦២-៦៣ (អង់គ្លេស)។

[9] *សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង Strugar*, លេខសំណុំរឿង IT-01-42-A, សាលដីកាលើបណ្តឹងសាទុក្ខ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៨, កថាខណ្ឌ ២១។

Original EN: 00877103-00877109

មិនចាំបាច់ និងតាមរយៈការខកខានពុំបានផ្តល់សារៈសំខាន់ទៅការពិចារណាពាក់ព័ន្ធ ដូចជាថាតើតម្រូវការវេជ្ជសាស្ត្ររបស់ លោក អៀង សារី អាចត្រូវបានបំពេញពីបន្ទប់សវនាការដែរ ឬយ៉ាងណា[10]។ សេចក្តីសង្កេតរបស់មេធាវីការពារក្តីពាក់ព័ន្ធនឹងសុខភាពរបស់កូនក្តីរបស់ខ្លួន អាចត្រូវបានផ្តល់សារៈសំខាន់ផ្នែកភស្តុតាង។ បើទោះបីជាមេធាវីការពារក្តីពុំមែនជាវេជ្ជបណ្ឌិតក៏ដោយ ក៏ខ្លួនជាមន្ត្រីនៃតុលាការដែលមានភារកិច្ចជួយតុលាការផងដែរ[11]។ មេធាវីការពារក្តីក៏ទាក់ទងជាទៀងទាត់ជាមួយជនជាប់ចោទដែរ។ ហេតុដូច្នេះ មេធាវីការពារក្តីស្ថិតនៅក្នុងតួនាទីពិសេសមួយ ដើម្បីផ្តល់ការយល់ដឹងអំពីផលប៉ះពាល់នៃស្ថានភាពផ្លូវកាយរបស់ជនជាប់ចោទ មកលើស្ថានភាពផ្នែកស្មារតីរបស់គាត់ ទាក់ទងនឹងលទ្ធភាពរបស់គាត់ក្នុងការដឹងខ្លួន និងផ្តង់អារម្មណ៍ចំពោះកិច្ចដំណើរការនីតិវិធី ។

៥. នៅក្នុងកថាខណ្ឌ ១៥-១៦ ក.ស.ព អះអាងថា អង្គជំនុំជម្រះសាលាដំបូងពុំទាន់បានបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងលោក អៀង សារី ឡើយ ហើយបណ្តឹងសាទុក្ខជំទាស់នឹងសេចក្តីសម្រេចដែលការបញ្ចប់កិច្ចដំណើរការនីតិវិធីស្ថិតនៅក្រោមការពិភាក្សា គឺពុំត្រូវបានអនុញ្ញាតឡើយ។ ចំណុចនេះបណ្តាលឲ្យមានការភ័ន្តច្រឡំ។ មេធាវីការពារក្តី*ពុំ*បានអះអាងថា កិច្ចដំណើរការនីតិវិធី *នឹងត្រូវបានបញ្ចប់* ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបានសម្រេចផ្សេងពីនេះឡើយ (ដែលនេះជាបញ្ហានៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ដែល ក.ស.ព បានលើកយកមកធ្វើជាសំអាង)។ មេធាវីការពារក្តីបានអះអាងថា កិច្ចដំណើរការនីតិវិធីត្រូវបានបញ្ចប់ប្រកបដោយប្រសិទ្ធភាពចំពោះលោក អៀង សារី ដោយហេតុថា ជាលទ្ធផលនៃសេចក្តីសម្រេចដែលត្រូវបានជំទាស់ គាត់នឹងពុំមានសមត្ថភាពដើម្បីចូលរួមប្រកបដោយអត្ថន័យនៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះឡើយ។

[10] *សូមមើល* បណ្តឹងសាទុក្ខ, កថាខណ្ឌ ៤៩។

[11] *សូមមើល* វិធាននៃក្រុមសីលធម៌វិជ្ជាជីវៈនៃរដ្ឋអាឡាស្កាឆ្នាំ ២០១២-២០១៣, វិធាន ៣.៣. ភាពស្មោះត្រង់ចំពោះតុលាការ "មេធាវីពុំត្រូវមានចេតនា៖ (១) ធ្វើសេចក្តីបញ្ជាក់មិនពិតអំពីអង្គហេតុ ឬអង្គច្បាប់ទៅតុលាការ ឬខកខានពុំបានកែប្រែសេចក្តីបញ្ជាក់មិនពិតអំពីអង្គហេតុ ឬអង្គច្បាប់គន្លឹះ ដែលមេធាវីនោះបានធ្វើទៅតុលាការកាលពីពេលមុន" ។ *សូមមើលផងដែរ* វិធានគំរូនៃគណៈមេធាវីអាមេរិកស្តីពីក្រុមសីលធម៌វិជ្ជាជីវៈ, វិធាន ៣.៣ (ភាសាដដែល)។ ក្រមសីលធម៌មេធាវីដែលបានចុះបញ្ជីនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា ២៤ ទំនាក់ទំនងជាមួយចៅក្រម៖ "[មេធាវី] ត្រូវបានហាមឃាត់យ៉ាងតឹងរ៉ឹងមិនឲ្យប្រព្រឹត្តទង្វើពុំស្មោះត្រង់ និងបង្កការរំខាន ..."។

Original EN: 00877103-00877109

*ភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខ ដោយអនុលោមតាមវិធាន ១០៤(៤)(ខ) - ចម្លើយតប កថាខណ្ឌ ១៧-២០*

៦. ត្រង់កថាខណ្ឌ ១៧-២០ ក.ស.ព អះអាងថា វិធាន ១០៤(៤)(ខ) បានត្រឹមតែអនុញ្ញាតឲ្យធ្វើបណ្តឹងសាទុក្ខជំទាស់នឹងសេចក្តីសម្រេចស្តីពីថាតើត្រូវឃុំខ្លួន ឬដោះលែងជនជាប់ចោទប៉ុណ្ណោះ។ ក.ស.ព អះអាងថា វិធាន ១០៤(៤)(ខ) ពុំដូចវិធាន ៧៤(៣)(ច) ឡើយ (វិធាននេះអនុញ្ញាតឲ្យប្តឹងសាទុក្ខជំទាស់នឹងសេចក្តីសម្រេចទាំងនេះ នៅដំណាក់កាលមុនការជំនុំជម្រះ) ត្រង់ចំណុចនេះ ដោយអះអាងថាវិធាន ៧៤(៣)(ច) គឺជាបញ្ញត្តិដែលមានលក្ខណៈទូលំទូលាយជាង[12]។ ក.ស.ព ខកខានពុំបានគាំទ្រអំណះអំណាងរបស់ខ្លួនដែលថាវិធាន ១០៤(៤)(ខ) គួរត្រូវបានបកស្រាយក្នុងន័យចង្អៀតជាងវិធាន ៧៤(៣)(ច) ឡើយ។ ជាការពិត ពុំមានយុត្តិកម្មសម្រាប់អនុញ្ញាតឲ្យមានបណ្តឹងសាទុក្ខប្រភេទនេះនៅដំណាក់កាលមុនការជំនុំជម្រះ ប៉ុន្តែ ហាមឃាត់បណ្តឹងសាទុក្ខប្រភេទនេះនៅដំណាក់កាលជំនុំជម្រះនោះទេ។ ផលប្រយោជន៍ដែលត្រូវបានការពារនៅដំណាក់កាលទាំងពីរនេះគឺជាផលប្រយោជន៍តែមួយ។

*ភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខ ដោយអនុលោមតាមវិធាន ១០៤(៤)(ឃ) - ចម្លើយតប កថាខណ្ឌ ២១-២៥*

៧. នៅក្នុងកថាខណ្ឌ ២១ ក.ស.ព អះអាងថា មេធាវីការពារក្តីស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលអនុវត្តវិធាន ៣៥ ចំពោះអង្គជំនុំជម្រះសាលាដំបូងនៅក្នុងការអនុវត្តមុខងារតាមផ្លូវតុលាការរបស់ខ្លួន។ វាជាការត្រឹមត្រូវដែលថា មេធាវីការពារក្តីស្នើសុំអនុវត្តវិធាន ៣៥ ចំពោះអង្គជំនុំជម្រះសាលាដំបូង។ វាពុំមែនជាការអនុវត្តដ៏ត្រឹមត្រូវរបស់អង្គជំនុំជម្រះសាលាដំបូងនូវមុខងារតាមផ្លូវតុលាការ ដើម្បីរំលោភសិទ្ធិជាសារវ័ន្តរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានអនុវត្ត តាមរយៈសេចក្តីសម្រេចដែលត្រូវបានជំទាស់ និងសេចក្តីសម្រេចពាក់ព័ន្ធនានាឡើយ[13]។

---

[12] ចម្លើយតប, កថាខណ្ឌ ១៩។

[13] *សូមមើល* បណ្តឹងសាទុក្ខ កថាខណ្ឌ ២៥ ដែលរៀបរាប់អំពីសេចក្តីសម្រេចដែល ទាក់ទងគ្នាដែលបានរំលោភសិទ្ធិជាសារវ័ន្តរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដើម្បីមានវត្តមានដោយផ្ទាល់នៅក្នុងការជំនុំជម្រះរបស់គាត់ និងដើម្បីរៀបចំការការពារក្តីតាមរយៈការធ្វើកំណត់ហេតុ។

៨. នៅក្នុងកថាខណ្ឌ ២២, ២៣ និង ២៥ ក.ស.ព អះអាងថាបណ្តឹងសាទុក្ខនេះពុំមានលក្ខណៈអាចឱ្យទទួលយកបាន ដោយអនុលោមតាមវិធាន ១០៤(៤)(ឃ) ដោយហេតុថា វាពុំមែនជាបណ្តឹងសាទុក្ខជំទាស់ទៅនឹងសំណើជាមូលដ្ឋានមួយដែលត្រូវបានធ្វើដោយអនុលោមតាមវិធាន ៣៥។ សំណើជាមូលដ្ឋានដែលស្នើសុំការអនុញ្ញាតឱ្យលោក អៀង សារី មានវត្តមាននៅក្នុងបន្ទប់សវនាការ ឬការថតវីដេអូចំពោះរូបគាត់ដែលជាជម្រើសម្យ៉ាងទៀត ពុំត្រូវបានធ្វើដោយអនុលោមតាមវិធាន ៣៥ ឡើយ ដោយហេតុថាពុំមានការរំលោភសិទ្ធិរបស់លោក អៀង សារី ឡើយ រហូតមកទល់នឹងពេលដែលសំណើនេះត្រូវបានបដិសេធ និងហេតុដូច្នេះ ពុំមានឡើយការជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលរបស់តុលាការកាលពីពេលនោះ។ វាជាការពុំសមហេតុផលក្នុងការកំហិតបណ្តឹងសាទុក្ខ ដោយអនុលោមតាមវិធាន ១០៤(៤)(ឃ) ត្រឹមតែចំពោះសេចក្តីសម្រេចនានាដែលត្រូវបានធ្វើ ដោយអនុលោមតាមសំណើក្រោមវិធាន ៣៥ ក្នុងករណីដែលដូចក្នុងករណីនាពេលបច្ចុប្បន្ន គឺសេចក្តីសម្រេច*នេះតែម្តង* ដែលជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលរបស់តុលាកា។ ប្រការនេះនឹងរារាំងភាគីពីការទទួលបានឧបាស្រ័យ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលរបស់តុលាការដោយខ្លួនឯងផ្ទាល់។ អង្គជំនុំជម្រះសាលាដំបូងពុំអាចស៊ើបអង្កេតដោយសមហេតុផលអំពីខ្លួនឯង ដោយអនុលោមតាមវិធាន ៣៥ បានឡើយ។ អង្គជំនុំជម្រះតុលាការកំពូលត្រូវតែស៊ើបអង្កេតអំពីការជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលរបស់តុលាការដែលអង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្ត[14]។

៩. ត្រង់កថាខណ្ឌ ២៤ ក.ស.ព លើកឡើងអំពីយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលដែលចែងថា៖ "គ្មានកំហុសអង្គច្បាប់ ឬអង្គហេតុ និងគ្មានការរំលោភនូវឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងណាមួយដែលអាចបង្កើតបានជាការជ្រៀតជ្រែកដោយដឹង និងមានចេតនាទៅលើកិច្ចការរដ្ឋបាលតុលាការ

[14] អង្គបុរេជំនុំជម្រះបានទទួលស្គាល់នៅក្នុងសេចក្តីសម្រេចសម្រាត់បំផុតមួយថា ជាការពុំត្រឹមត្រូវដែលការិយាល័យមួយនៃតុលាការត្រូវស៊ើបអង្កេតអំពីការចោទប្រកាន់នានាដែលថាខ្លួនបានជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលរបស់តុលាការ ដោយហេតុថាអាចមានទំនាស់ផលប្រយោជន៍ ឬការយល់ឃើញសមហេតុផលថាមានភាពលម្អៀងនៅក្នុងករណីទាំងនោះ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថាវិធាន ៣៥(២) ពុំសំដៅទៅដល់អង្គជំនុំជម្រះជាក់លាក់ណាឡើយ ប៉ុន្តែបានត្រឹមតែគូសបញ្ជាក់ថា "អង្គជំនុំជម្រះ" អាចដោះស្រាយការជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលរបស់តុលាការ។ *សូមមើល* សំណុំរឿង 002/14-12-2009-អ.វ.ត.ក/អ.ប.ជ (08), ឯកសារលេខ ៣។

Original EN: 00877103-00877109

ដោយយោងតាមអត្ថន័យនៃវិធាន ៣៥ នៃវិធានផ្ទៃក្នុងឡើយ”[15]។ ដូចដែលបានពន្យល់នៅក្នុងកថាខណ្ឌ ២៥ នៃបណ្ដឹងសាទុក្ខ សេចក្ដីសម្រេចដែលត្រូវបានជំទាស់*តែឯកឯង* ពុំមែនជាហេតុការណ៍មួយដាច់ដោយឡែក ដែលបានជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលរបស់តុលាការឡើយ។ ជំនួសមកវិញ វាជាផ្នែកមួយនៃសេចក្ដីសម្រេចមួយបណ្ដុំដែលទាក់ទងគ្នាទៅវិញទៅមក ដែលតាមរយៈនេះអង្គជំនុំជម្រះសាលាដំបូងបានជ្រៀតជ្រែក ដោយចេតនាពិតប្រាកដជាបន្តបន្ទាប់ចូលកិច្ចការរដ្ឋបាលរបស់តុលាការ តាមរយៈការរំលោភសិទ្ធិជាសារវ័ន្តរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដើម្បីមានវត្តមានដោយផ្ទាល់នៅក្នុងសវនាការរបស់គាត់ និងដើម្បីរៀបចំការការពារខ្លួនរបស់គាត់តាមរយៈការធ្វើកំណត់ហេតុ។

*ថាតើលទ្ធភាពនៃការអនុញ្ញាតឱ្យមានការថតវីដេអូចំពោះលោក អៀង សារី នៅតែស្ថិតក្រោមការពិចារណានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង - ចម្លើយតប កថាខណ្ឌ ២៦-៣១ ដែរឬយ៉ាងណា*

១០. ត្រង់កថាខណ្ឌ ២៦-៣១ ក.ស.ព អះអាងថាបញ្ហាថាតើអង្គជំនុំជម្រះសាលាដំបូងបានបំពានឆន្ទានុសិទ្ធិរបស់ខ្លួនតាមរយៈការបដិសេធពុំអនុញ្ញាតឱ្យថតវីដេអូចំពោះ លោក អៀង សារី គឺពុំទាន់គ្រប់គ្រាន់សម្រាប់ការពិចារណា ដោយហេតុថា នាពេលបច្ចុប្បន្ន អង្គជំនុំជម្រះសាលាដំបូងកំពុងពិនិត្យមើលឡើងវិញអំពីនិត្យានុកូលភាពនៃការថតខ្សែអាត់សំឡេង និងវីដេអូ។ ក្នុងការគាំទ្រ ក.ស.ព លើកឡើងអំពីការបង្គាប់ឱ្យដាក់សារណារបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២[16]។ តាមរយៈការបង្គាប់ឱ្យដាក់សារណានេះ អង្គជំនុំជម្រះសាលាដំបូង “បានបង្គាប់ឱ្យមេធាវីការពារក្ដីបញ្ឈប់*ការថតខ្សែអាត់សំឡេង*នេះជាបន្ទាន់” និងបានគូសបញ្ជាក់ថា “ប្រសិនបើមេធាវីការពារក្ដី អៀង សារី មានបំណងចង់បន្ត*ការថតខ្សែអាត់សំឡេង*របស់ជនជាប់ចោទ និង/ឬគ្រូពេទ្យព្យាបាលជនជាប់ចោទនោះ មេធាវីការពារក្ដី អៀង សារី ត្រូវស្នើសុំការអនុញ្ញាតជាមុនដោយអនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង ដោយបញ្ជាក់អំពីហេតុផលទាំងឡាយដែលអាចអនុញ្ញាតឱ្យធ្វើដូច្នេះក្រោមក្របខណ្ឌគតិ

---

[15] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឱ្យជនជាប់ចោទមានវត្តមានក្នុងសាលសវនាការ, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១២, ឯកសារ E130/4/3, ទំព័រ ១ (អង់គ្លេស)។

[16] ការបង្គាប់ឱ្យដាក់សារណា, ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២, ឯកសារ E254។

យុត្ត អ.វ.ត.ក"[17]។ ការលើកឡើងតែម្តងគត់អំពីការថតវីដេអូចំពោះលោក អៀង សារី គឺនៅប្រយោគចុងក្រោយនៃលិខិតបង្គាប់នេះ៖ "ការធ្វើសេចក្តីសង្កេតណាមួយរបៀបនេះតទៅទៀតអំពីស្ថានភាពរបស់ អៀង សារី ទោះជាធ្វើឡើងតាមរយៈការថតជាខ្សែអាត់សំឡេង ការថតជាវីដេអូ ការសង្កេតរបស់ក្រុមមេធាវីការពារក្តី អៀង សារី ឬតាមមធ្យោបាយផ្សេងពីនេះក្តី ត្រូវបានហាមឃាត់រហូតដល់ពេលមានការសម្រេចទៅលើលទ្ធភាពនៃការអនុញ្ញាតឱ្យមានការអនុវត្តបែបនេះ ដោយអង្គជំនុំជម្រះសាលាដំបូង"។ ការបង្គាប់នេះនិយាយអំពីការថតខ្សែអាត់សំឡេង និងកំណត់ហេតុនៃការសង្កេតប្រចាំថ្ងៃដែលមេធាវីការពារក្តីបានដាក់។ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចដែលត្រូវបានជំទាស់ ខ្លួនពុំបានគូសបញ្ជាក់ថាសេចក្តីសម្រេចរបស់ខ្លួនដើម្បីហាមឃាត់ការថតវីដេអូ គឺជាសេចក្តីសម្រេចបណ្តោះអាសន្ន ឬរង់ចាំការពិនិត្យមើលឡើងវិញបន្ថែមទៀតឡើយ[18]។ ការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូងដែលពុំអនុញ្ញាតឱ្យថតវីដេអូចំពោះលោក អៀង សារី ហាក់ដូចជាការបដិសេធស្ថាពរ។ ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលមានបំណងបដិសេធផ្នែកនេះនៃបណ្តឹងសាទុក្ខ ដោយហេតុថាបញ្ហានេះពុំទាន់គ្រប់គ្រាន់សម្រាប់ការពិចារណា មេធាវីការពារក្តីសូមស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលសួរទៅអង្គជំនុំជម្រះសាលាដំបូងជាមុនសិន ថាតើអង្គជំនុំជម្រះសាលាដំបូងមានចេតនាពិចារណាឡើងវិញអំពីគោលជំហររបស់ខ្លួនស្តីពីការថតវីដេអូ ឬថាតើជំនួសមកវិញការបង្គាប់ឱ្យដាក់សារណាសំដៅត្រឹមតែទៅលើការថតខ្សែអាត់សំឡេង និងកំណត់ហេតុនៃការសង្កេតប្រចាំថ្ងៃ ដែរឬយ៉ាងណា។

សូមអង្គជំនុំជម្រះទទួលនូវក្តីគោរពអំពីយើងខ្ញុំ។

| | |
|---|---|
| ______________ | ______________ |
| អាង ឧត្តម | Michael G. KARNAVAS |

សហមេធាវីរបស់លោក អៀង សារី

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **០៩** ខែ **មករា** ឆ្នាំ **២០១៣**

---

[17] *សូមមើលឯកសារយោងខាងលើ* (សេចក្តីបញ្ជាក់បន្ថែម)។

[18] *សូមមើល* បណ្តឹងសាទុក្ខ, កថាខណ្ឌ ១៦, *ដែលដកស្រង់* ប្រតិចារឹក, ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១២, ឯកសារ E1/147.1។

Original EN: 00877103-00877109